មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ត្រូវជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៦៩៩/១៣៨

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់ សេចក្តីស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១.- កែសម្រួលខ្លឹមសារនៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដូចខាងក្រោម :

## ជំពូកទី ១

## នីតិសារជាតិ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

មាត្រា ២.- បានត្រូវបង្កើតឡើងនូវមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ហៅកាត់ថា ម.ស.ម.ក ។ ម.ស.ម.ក ជាគ្រឹះស្ថានសាធារណៈប្រកបដោយបុគ្គលភាពគតិយុត្ត ដែលស្ថិតនៅក្រោមអាណាព្យាបាល នៃនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ម.ស.ម.ក មានសិទ្ធិដើម្បី :

ក- ចុះកិច្ចសន្យា ឬបំពេញកាតព្វកិច្ចផ្សេងទៀត ដើម្បីឲ្យសំរេចបេសកកម្មរបស់ខ្លួន ។

ខ- ជ្រើសរើស និងប្រើប្រាស់បុគ្គលិកទាំងឡាយ ដែលចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

មាត្រា ៣.- ម.ស.ម.ក មិនត្រូវធ្វើសកម្មភាពពាណិជ្ជកម្មណាមួយឡើយ ។

## ជំពូកទី ២

## គោលដៅ និង សកម្មភាព

មាត្រា ៤.- ម.ស.ម.ក ត្រូវមានភារកិច្ចធ្វើការសំរបសំរួលរាល់សកម្មភាពកំចាត់មីនទាំងអស់ ។

មាត្រា ៥.- ម.ស.ម.ក អាចចែករំលែកបច្ចេកទេស និងការពិសោធន៍របស់ខ្លួនទៅឲ្យប្រទេសទាំងឡាយណាដែលមានបញ្ហាមីន ។

មាត្រា ៦.- ម.ស.ម.ក ត្រូវកំណត់ឲ្យបានច្បាស់ និងអនុវត្តកម្មវិធី ដូចតទៅ :

ក- ការយល់ដឹងអំពីគ្រោះថ្នាក់មីន

ខ- ព័ត៌មានអំពីចំការមីន និងការដាក់ផ្លាកសញ្ញាមីន

គ- ការបោសសំអាតមីន រួមបញ្ចូលទាំងការកំទេចគ្រឿងផ្ទុះចោល

ឃ- ការហ្វឹកហ្វឺនក្នុងការសំអាតមីន ។

ម.ស.ម.ក ត្រូវចាត់វិធានការផ្តល់សុវត្ថិភាពឲ្យបានកំរិតខ្ពស់ដល់បុគ្គលិកទាំងអស់របស់ខ្លួន ។

មាត្រា ៧.- កម្មវិធីខាងលើ ត្រូវអនុវត្តក្នុងគោលបំណងសន្តិភាពតែប៉ុណ្ណោះ និងត្រូវប្រព្រឹត្តទៅតាមលំដាប់អាទិភាព ដូចតទៅ :

ក- តាមផ្លូវមនុស្សធម៌ ដើម្បីជួយជនភៀសខ្លួនដែលមកតាំងទីលំនៅថ្មី និងជួយដល់ការចាប់ដីនៅប្រភេទផ្សេង ៗទៀត ។

ខ- តាមផ្លូវសេដ្ឋកិច្ច ដើម្បីជួយពង្រីកកសិកម្ម និងដើម្បីជួយស្តារ ឬកសាងជាតិឡើងវិញ ឬតាមគំរោងការអភិវឌ្ឍន៍ ។

គ- តាមផ្លូវផ្សេងៗទៀត ។

## ជំពូកទី ៣

## ការគ្រប់គ្រងមជ្ឈមណ្ឌល

មាត្រា ៨.- ម.ស.ម.ក ត្រូវមាន :

ក- ក្រុមប្រឹក្សាភិបាលមួយ

ខ- ប្រធានមួយ (១) រូប អនុប្រធាន (១) រូប

គ- អគ្គនាយកមួយ (១) រូប

ឃ- ហិរញ្ញិកមួយ (១) រូប

ង- អង្គភាពរដ្ឋបាល និងបច្ចេកទេស

## ជំពូកទី ៤

## ក្រុមប្រឹក្សាភិបាល

មាត្រា ៩.- ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកយ៉ាងតិច ១៥រូប ដែលអាចមានសមាជិកអន្តរជាតិនៅក្នុងចំណោមនោះផង ។ សមាជិកជាតិ ត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

មាត្រា ១០.- ក្រុមប្រឹក្សាភិបាលត្រូវមានប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប អគ្គនាយកមួយ (១) រូប សមាជិកនានា និងអគ្គលេខាធិការដ្ឋានមួយ ។ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជាស្វ័យប្រវត្តិជាប្រធាននៃក្រុមប្រឹក្សាភិបាល ។ ក្នុងករណីដែលនាយករដ្ឋមន្ត្រីមិនអាចបំពេញមុខនាទីនេះដោយផ្ទាល់បាន នាយករដ្ឋមន្ត្រីអាចស្នើថ្វាយព្រះមហាក្សត្រ ដើម្បីតែងតាំងតំណាងម្នាក់ជាប្រធាននៃក្រុមប្រឹក្សាភិបាល ។ ប្រធានក្រុមប្រឹក្សាភិបាល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យនោះ ជាប្រធានមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។ អនុប្រធានក្រុមប្រឹក្សាភិបាលត្រូវបានស្នើតែងតាំងស្របពេលគ្នានឹងការស្នើតែងតាំងក្រុមប្រឹក្សាភិបាល ។

មាត្រា ១១.- គណៈអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាភិបាលត្រូវបានបង្កើតឡើងរួមមានសមាសភាពគឺ ប្រធានក្រុមប្រឹក្សាភិបាល អនុប្រធាន និងអគ្គនាយក ។ គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាភិបាល

ទទួលខុសត្រូវដោយឯកភាពគ្នា ក្នុងការតាមដាននិងចាត់ចែងអនុវត្ត នូវរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១២.-** សមាជិកខ្មែរដទៃទៀតនៃក្រុមប្រឹក្សាភិបាល ជាតំណាងរដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ តំណាងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ តំណាងរដ្ឋមន្ត្រី ក្រសួងការបរទេស ក្រៅពីនោះជាវរៈជនសំខាន់ៗដទៃទៀត ។ សមាជិកអន្តរជាតិអាចតែងតាំងដោយនាយករដ្ឋមន្ត្រីក្នុងករណីមានការស្នើសុំពីប្រទេសផ្តល់ជំនួយ ។

**មាត្រា ១៣.-** ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន ត្រូវប្រគល់សិទ្ធិឲ្យអនុប្រធានទទួលតំណែងជាប្រធានក្រុមប្រឹក្សាភិបាលស្តីទី ។

**មាត្រា ១៤.-** អគ្គនាយកនៃ អ.ស.អ.ក ត្រូវបានចាត់តាំងជាអគ្គលេខាធិការ នៃក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៥.-** ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុអាចចូលរួមក្នុងក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកសង្កេតការណ៍ ដែលមិនត្រូវមានចំនួនលើសពីពីរនាក់ទេ ។

**មាត្រា ១៦.-** ប្រទេសផ្តល់ជំនួយអាចចូលរួមក្នុងក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

**មាត្រា ១៧.-** ក្រុមប្រឹក្សាភិបាលត្រូវមានអាណត្តិចំនួន ពីឆ្នាំ ហើយសមាជិកនៃក្រុមប្រឹក្សានេះ អាចត្រូវបានតែងតាំងជាថ្មីទៀត ។ សមាជិកភាព នៃតំណាងអចិន្ត្រៃយ៍របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងហិរញ្ញវត្ថុ និងក្រសួងការបរទេស គ្មានកំណត់អាណត្តិឡើយ ។

**មាត្រា ១៨.-** ក្រុមប្រឹក្សាភិបាលត្រូវបើកកិច្ចប្រជុំសាមញ្ញមួយដង ក្នុងមួយត្រីមាស ហើយនិងកិច្ចប្រជុំប្រចាំឆ្នាំមួយនៅដំណាច់ឆ្នាំហិរញ្ញវត្ថុ ។ គណៈអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាភិបាល ឬសមាជិកភាគច្រើន នៃក្រុមប្រឹក្សាភិបាលអាចកោះកិច្ចប្រជុំវិសាមញ្ញបាន ។

**មាត្រា ១៩.-** កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនឹងយកជាការបាន លុះត្រាតែមានសមាជិកភាគច្រើនដាច់ខាតចូលរួម ។ នៅពេលដែលមានសមាជិកខ្មែរផង និងសមាជិកអន្តរជាតិផង ក្នុងចំណោមចំនួនដ៏តិចបំផុតសំរាប់ប្រជុំនេះ អង្គប្រជុំត្រូវមានសមាជិកអន្តរជាតិយ៉ាងហោចក៏មួយនាក់ដែរ ទើបយកជាបានការ ។ ក្រោយដែលមិនបានសមាជិកភាគច្រើនចូលរួម គេត្រូវអញ្ជើញសមាជិកទាំងអស់ម្តងទៀតមកប្រជុំ ហើយសមាជិកដែលមានវត្តមានក្រោយការជំរាបអញ្ជើញនេះ នឹងយកជាបានការដើម្បីធ្វើកិច្ចប្រជុំ ។

**មាត្រា ២០.-** សមាជិកអាចចាត់អ្នកតំណាងរបស់ខ្លួនឲ្យចូលរួមប្រជុំក្រុមប្រឹក្សាភិបាល ។ សមាជិកម្នាក់ៗ ឬអ្នកតំណាងរបស់ខ្លួនត្រូវមានសិទ្ធិមានឆ្នោតតែមួយគត់ ។ សេចក្តីសំរេចនឹងយកជាការ

បាន ហើយមានសមាជិកភាគច្រើនបោះឆ្នោតគាំទ្រ ។ នៅពេលដែលមានសមភាពរវាងសន្លឹកឆ្នោតគាំទ្រ និងសន្លឹកឆ្នោតប្រឆាំង ប្រធានត្រូវធ្វើសេចក្តីសម្រេចជាចុងក្រោយ ។

មាត្រា ២១.- ក្រុមប្រឹក្សាភិបាលត្រូវមានមុខងារ ដូចតទៅ ៖

ក- តាមពិនិត្យមើលសកម្មភាព ម.ស.ម.ក ហើយនឹងផ្តល់ការណែនាំដើម្បីធ្វើឲ្យកិច្ចប្រតិបត្តិការប្រព្រឹត្តទៅស្របនឹងគោលដៅ ហើយនឹងសកម្មភាពរបស់មជ្ឈមណ្ឌលដែលមានចែងក្នុងជំពូកទី ២ ស្រាប់ ។

ខ- អនុម័តយល់ព្រមលើកម្មវិធី ផែនការការងារ ថវិកា ធនធានមនុស្ស ហើយនឹងរបាយការណ៍របស់ ម.ស.ម.ក ។

គ- អនុម័តយល់ព្រមលើបទបញ្ជាផ្ទៃក្នុងទាំងឡាយរបស់ ម.ស.ម.ក ស្តីអំពីការរៀបចំអង្គការ អំពីហិរញ្ញវត្ថុ និងអំពីបុគ្គលិក ។

ឃ- សម្រេចលើបញ្ហាទាំងឡាយ ដែលទាក់ទងនឹង ម.ស.ម.ក ។

មាត្រា ២២.- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នឹងចូលជាធរមានប្រាំពីរថ្ងៃក្រោយដែលបានអនុម័តរួច លើកលែងតែការងារខ្លះដែលត្រូវចាត់ការជាចាំបាច់ និងបន្ទាន់ ។

មាត្រា ២៣.- ក្រុមប្រឹក្សាភិបាល ត្រូវមានបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់របៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សាភិបាល និងបែងចែកភារកិច្ចទទួលខុសត្រូវដល់សមាជិកនានា ។

## ជំពូកទី៥

## អគ្គនាយក

មាត្រា ២៤.- អគ្គនាយក ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ សំរាប់អាណត្តិ បីឆ្នាំ ស្របពេលគ្នានឹងការតែងតាំងក្រុមប្រឹក្សាភិបាល ។ ការតែងតាំងនេះអាចធ្វើឡើងវិញជាថ្មីបានក្នុងករណីចាំបាច់ ដោយមានការស្នើពីសំណាក់ក្រុមប្រឹក្សា ភិបាលទៅគណៈរដ្ឋមន្ត្រី ។

មាត្រា ២៥.- អគ្គនាយកអាចស្នើការជ្រើសរើសអគ្គនាយករង ០១នាក់ ទៅក្រុមប្រឹក្សាភិបាល ។ អគ្គនាយករងនេះ ត្រូវតែងតាំងឡើងដោយអនុក្រឹត្យ ។

មាត្រា ២៦.- អគ្គនាយកទទួលសិទ្ធិពីប្រធាន ដើម្បីដឹកនាំចាត់ចែងការងារទូទៅក្នុង ម.ស.ម.ក ។

មាត្រា ២៧.- អគ្គនាយកត្រូវមានមុខការជាអាទិ៍ ដូចតទៅ :

ក- រៀបចំចាត់ចែង និងគ្រប់គ្រង ម.ស.ម.ក ទៅតាមលក្ខន្តិកៈនេះ ។

ខ- អនុវត្តតាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

គ- ដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយល់ព្រមនូវកម្មវិធី ផែនការការងារ គំរោងថវិកា គណនេយ្យ ហើយនិងរបាយការណ៍ប្រចាំឆ្នាំរបស់ អ.ស.អ.ក ។

ឃ- ដាក់ជូនក្រសួងហិរញ្ញវត្ថុ ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ហើយនិងប្រទេសផ្តល់ជំនួយផ្សេងៗ នូវគណនេយ្យ និងរបាយការណ៍ប្រចាំឆ្នាំរបស់ អ.ស.អ.ក ។

ង- ដឹកនាំកម្មវិធីការងារ អ.ស.អ.ក ហើយនិងអនុញ្ញាតចំណាយដែលមានចែងក្នុងថវិកា ។

ច- តែងតាំង ដឹកនាំបុគ្គលិក និងតំឡើងឋានន្តរស័ក្តិរបស់បុគ្គលិកនៃ អ.ស.អ.ក ហើយនិងដាក់វិន័យទៅតាមបទបញ្ជា ដែលក្រុមប្រឹក្សាភិបាលបានអនុម័តយល់ព្រម ហើយដើម្បីលើកកំពស់ប្រសិទ្ធភាពនៃអង្គភាព និងការស្ថាបនាក្នុងការធ្វើការងារឲ្យបានកាន់តែខ្ពស់ជាទីបំផុត ។

ឆ- ទទួលខុសត្រូវអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាភិបាល ។

មាត្រា ២៨.- ក្នុងការបំពេញភារកិច្ចទាំងឡាយនេះ អគ្គនាយកអាចតែងតាំងជំនួយការ និងទីប្រឹក្សាបច្ចេកទេសមួយចំនួន ។

មាត្រា ២៩.- អគ្គនាយកអាចផ្ទេរអំណាចរបស់ខ្លួនទៅបុគ្គលិកក្រោមឱវាទ ។ អគ្គនាយកអាចចែករំលែកអំណាចក្នុងការចាត់ចែងហិរញ្ញវត្ថុនៃ អ.ស.អ.ក ទៅ ឲ្យហិរញ្ញិក ។

## ជំពូកទី៦

## ហិរញ្ញិក

មាត្រា ៣០.- អ.ស.អ.ក ត្រូវមានហិរញ្ញិកមួយនាក់ ។ អគ្គនាយកត្រូវស្នើការតែងតាំងហិរញ្ញិកនេះ ទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការអនុម័តយល់ព្រមជាស្ថាពរ ។ ហិរញ្ញិកអាចជាបុគ្គលិកខ្មែរ ឬជាបុគ្គលិកអន្តរជាតិ ។ ភ្នាក់ងារផ្តល់ជំនួយអាចស្នើ ការតែងតាំងហិរញ្ញិកនេះបាន ។

មាត្រា ៣១.- ហិរញ្ញិកត្រូវមានមុខងារជាអាទិ៍ ដូចតទៅ ៖

ក- ជួយរៀបចំកិច្ចព្រមព្រៀងអំពីគំរោងការរវាង អ.ស.អ.ក. និងភ្នាក់ងារផ្តល់ជំនួយ ។

ខ- បំពេញមុខការចាំបាច់ទាំងឡាយខាងហិរញ្ញវត្ថុ និងខាងគណនេយ្យសំរាប់ អ.ស.អ.ក. រាប់បញ្ចូលទាំងការថែរក្សាមូលនិធិរបស់មជ្ឈមណ្ឌលរួមគ្នាជាមួយនឹងអគ្គនាយក ។

គ- ជួយរៀបចំគំរោងថវិកា ។

ឃ- ជួយរៀបចំច្បាប់ទាំងឡាយខាងផ្នែកហិរញ្ញវត្ថុ សំរាប់ដាក់ជូនក្រុមប្រឹក្សាភិបាលសំរេចអនុម័ត ។

ង- ជួយធ្វើឲ្យមានការអនុវត្តន៍ច្បាប់ខាងលើនេះ ។

ច- បើកប្រាក់ចំណាយដោយមានការអនុញ្ញាតពីអគ្គនាយក ម.ស.ម.ក. ។

ឆ- រៀបចំ និងបញ្ជាក់និយ័តភាពគណនេយ្យប្រចាំឆ្នាំ ។

ជ- ជួយរៀបចំចាត់ចែងសម្ភារៈ និងជួយមើលការទិញសំភារៈ ព្រមទាំងចាត់ចែងសំភារៈបរិក្ខាររបស់ ម.ស.ម.ក.ឲ្យបានត្រឹមត្រូវ ។

ឈ- ជួយរៀបចំឯកសារទាំងឡាយ ដែលត្រូវដាក់ជូនភ្នាក់ងារផ្តល់ជំនួយ ។

ញ- ជួយសំរួលការត្រួតពិនិត្យគណនេយ្យរបស់ ម.ស.ម.ក. ។

ដ- ធ្វើសេចក្តីរាយការណ៍អំពីចំណូល-ចំណាយរៀងរាល់ខែ ជូនក្រុមប្រឹក្សាភិបាល ។

មាត្រា ៣២.- ហិរញ្ញិកត្រូវបំពេញមុខងារជានាយកគណនេយ្យ នៃ ម.ស.ម.ក ។

## ជំពូកទី ៧

## អង្គភាពរដ្ឋបាល និង បច្ចេកទេស

មាត្រា ៣៣.- ម.ស.ម.ក ត្រូវមានអង្គភាពរដ្ឋបាល និងបច្ចេកទេស ដែលចាំបាច់ក្នុងការបំពេញភារកិច្ច និងដើម្បីឲ្យបានសំរេចគោលបំណងរបស់ខ្លួន ។ ម.ស.ម.ក. ត្រូវមានបុគ្គលិករដ្ឋបាល និងបច្ចេកទេស ដែលមានការអប់រំហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវ និងគុណសម្បត្តិខ្ពស់ ដើម្បីចាត់ចែងអង្គភាពទាំងនេះ ។ ម.ស.ម.ក. ត្រូវជាស្ថាប័នមួយដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និងភាពស្អាតស្អំ ។

មាត្រា ៣៤.- រចនាសម្ព័ន្ធ និងការរៀបចំអង្គការរបស់ ម.ស.ម.ក. ត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

## ជំពូកទី ៨

## ការចាត់ចែងហិរញ្ញវត្ថុ

មាត្រា ៣៥.- ម.ស.ម.ក. ជាស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលមានទិសដៅមិនស្វែងរកចំណេញឡើយ ។ ម.ស.ម.ក. ត្រូវមានថវិការបស់ខ្លួនសំរាប់ការរៀបចំប្រព្រឹត្តទៅ និងសំរាប់កិច្ចប្រតិបត្តិការទាំងឡាយរបស់ខ្លួន ។

មាត្រា ៣៦.- ម.ស.ម.ក. អាចសុំ អាចទទួល អាចទិញ ឬជួលនោះទេ អាចគុំពីស្ថាប័នរដ្ឋាភិបាល ឬអន្តររដ្ឋាភិបាល ឬពីបុគ្គលឯក ឬក៏ពីក្រុមហ៊ុន ឬក៏ពីស្ថាប័នឯទៀតៗ ដោយអំណោយក្ដី ឬក៏ដោយមធ្យោបាយឯទៀតណាក៏ដោយក្ដី នូវធនធានទាំងឡាយរាប់ទាំងប្រាក់កាស និងអំណោយដែលមានប្រយោជន៍ ឬដែលត្រូវការចាំបាច់ក្នុងការធ្វើឲ្យសំរេចគោលដៅរបស់ខ្លួន ។ ម.ស.ម.ក. អាចរក្សាទុក អាចជាម្ចាស់ អាចគ្រប់គ្រង អាចប្រើប្រាស់ អាចផ្ទេរបន្ត ឬក៏អាចលក់ចេញ ឬក៏ផ្ដល់ឲ្យអ្នកដទៃនូវធនធានទាំងនោះ ។ ម.ស.ម.ក. អាចទិញចលនវត្ថុ ឬអចលនវត្ថុណាដែលឃើញថា ចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

មាត្រា ៣៧.- ម.ស.ម.ក. អាចសុំ អាចទទួល អាចទិញ ឬជួលនោះទេ អាចគុំហោពីស្ថាប័ន រដ្ឋាភិបាល ឬអន្តររដ្ឋាភិបាល ឬពីបុគ្គល ឬក៏ពីក្រុមហ៊ុន ឬក៏ពីស្ថាប័នឯទៀតនូវសិទ្ធិការអនុញ្ញាត ការផ្ទេរប្រគល់ឲ្យ ហើយនឹងជំនួយឧបត្ថម្ភ ទោះជាហិរញ្ញវត្ថុក្ដី ឬប្រភេទណាផ្សេងទៀតក្ដី ដែលជួយសំរួលក្នុងការធ្វើឲ្យគោលដៅរបស់ខ្លួនបានសំរេច ។

មាត្រា ៣៨.- ម.ស.ម.ក. អាចឲ្យបុគ្គលឯកជន ឬក្រុមហ៊ុន ឬឯកជនផ្សេងទៀត បង់ប្រាក់លើផលិតផល ឬសេវាកម្មដែលខ្លួនផ្ដល់ឲ្យ ។ ថ្លៃទាំងនេះ មិនត្រូវឲ្យហួសលើសពីតំលៃផលិតកម្មឡើយ ។

មាត្រា ៣៩.- ម.ស.ម.ក. ត្រូវមានបែបបទហិរញ្ញវត្ថុរបស់ខ្លួន ហើយត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុ ឲ្យទៀងទាត់ជូនទៅក្រុមប្រឹក្សាភិបាល ភ្នាក់ងារផ្ដល់ហិរញ្ញវត្ថុ ហើយនឹងប្រទេសផ្ដល់ជំនួយ ។

មាត្រា ៤០.- គណនេយ្យចំណាយ-ចំណូល ម.ស.ម.ក. ត្រូវបើកចំហរឲ្យមានការត្រួតពិនិត្យតែកគេរ ពីសំណាក់អង្គការឯករាជ្យណាមួយ ឬពីសំណាក់ភ្នាក់ងារផ្ដល់ហិរញ្ញវត្ថុ ឬប្រទេសផ្ដល់ជំនួយឧបត្ថម្ភ ។

មាត្រា ៤១.- ម.ស.ម.ក. ត្រូវបានជាម្ចាស់សម្បត្តិទាំងឡាយ ដែលខ្លួនរកបាន ។

មាត្រា ៤២.- ម.ស.ម.ក. ត្រូវបានរួចពីពន្ធគយលើទំនិញទាំងឡាយដែលខ្លួនទិញ ឬក៏ទទួលជាអំណោយ សំរាប់ការកកើត និងប្រព្រឹត្តទៅ ហើយនឹងសកម្មភាពរបស់ខ្លួន ។

## ជំពូកទី ៩

## ការជាប់សំណង និង វិវាទ

មាត្រា ៤៣.- បុគ្គលិក និងសមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក. នឹងមិនត្រូវជាប់សំណងផ្ទាល់ខ្លួន ប្រភេទណាមួយឡើយ ដោយការខូចខាតដល់អ្នកឯទៀត ដែលបណ្ដាលមកពីសកម្មភាពខ្លួន នៅពេលបំពេញមុខងារផ្លូវការរបស់ខ្លួន ។

**មាត្រា ៤៤.-** អ.ស.អ.ក. ត្រូវទទួលខុសត្រូវចំពោះការកើតក្តីឲ្យសងសំណងនេះ ទៅតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា ៤៥.-** អ.ស.អ.ក. ចេញមុខការពារ ឬប្តឹងតវ៉ាជំនួសក្នុងករណីដែលមានវិវាទ ។ អ.ស.អ.ក. មានភារកិច្ចចេញមុខការពារតវ៉ា ឬដោះស្រាយការទាមទារ ឬបណ្តឹងផ្សេងៗទៀត ដែលបណ្តាលមកពីសកម្មភាព ឬកិច្ចប្រតិបត្តិការនៃ អ.ស.អ.ក. រាប់ទាំងប្រាក់ចំណាយនៃរឿងវិវាទ នោះផង ។

## ជំពូកទី១០

## រំលាយ

**មាត្រា ៤៦.-** អ.ស.អ.ក. ត្រូវរលាយនៅពេលណាដែលមានការប្រព្រឹត្តទៅ របស់ពេលដែលខ្លួនបានបំពេញបេសកកម្មរបស់ខ្លួនចប់សព្វគ្រប់ហើយ ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការសម្រេចអំពីការបញ្ចប់បេសកកម្មនេះ ហើយនិងអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ អ.ស.អ.ក. ដែលនៅសល់ក្រោយពីបានសងបំណុលគេទាំងអស់ ។ ការបញ្ចប់បេសកកម្មនៃ អ.ស.អ.ក. ហើយនិងការផ្ទេរភោគទ្រព្យដែលខ្លួនមាន ហើយនិងបំណុលរបស់ខ្លួន ត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

## ជំពូកទី១១

## អវសានប្បញ្ញត្តិ

**មាត្រា ៤៧.-** នៅពេលដែលពុំទាន់មានការតែងតាំងលើកដំបូង អគ្គនាយកត្រូវទទួលបន្ទុកមុខនាទីនេះ នៅចំពោះមុខក្រុមប្រឹក្សាភិបាល ។

**មាត្រា ៤៨.-** គ្រប់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤៩.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥០.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

★★★